www.kidworship.kr

# ចំណងជើង៖ ព្រះយេស៊ូព្យាបាលជំងឺ (បុរសខ្វិន)



36Page

Narration　គ្រប់ទាំងរាស្ត្រអ៊ីស្រាអ៊ែលសុទ្ធតែបានដឹងអំពីដំណឹងរបស់ព្រះយេស៊ូក្នុងការព្យាបាលអ្នកជំងឺ។ ដូច្នេះហើយហ្វូងមនុស្សបានប្រមូលផ្តុំគ្នាគ្រប់ទីកន្លែងដែលព្រះយេស៊ូបានទៅ។ថ្ងៃមួយព្រះយេស៊ូបានចូលទៅក្នុងភូមិមួយឈ្មោះ កាពើណិម។

ហ្វូងមនុស្ស　ព្រះយេស៊ូពិតជាអស្ចារ្យណាស់!!

Narration　នៅកាពើណិម មានមនុស្សខ្វិនម្នាក់គាត់រស់នៅទីនោះ គាត់ពុំអាចដើរបាន ឬក៏ពិសារអាហារដោយខ្លួនឯងបានស្រួលនោះឡើយ។

មនុស្សខ្វិន　ខ្ញុំពិតជាពិបាកខ្លាំងណាស់។ តើខ្ញុំអាចចូលទៅកាន់ព្រះយេស៊ូ ដោយរបៀបណាបានទៅ បើខ្ញុំមិនអាចដើរបានផងនោះ?

មិត្តភ័ក្ត　ខ្ញុំនឹងជួយអ្នក

..........................................................................................



37Page

Narration　មិត្តភក្តិរបស់ជនពិការក៏បាននាំគ្នាយកបុរសពិការនោះទៅជួបព្រះយេស៊ូ។ ពួកគេបានធ្វើគ្រែស្នែងសំរាប់គាត់ ដោយយកឈើហើយនឹងក្រណាត់ក្រាស់ៗដើម្បីធ្វើជាគ្រែស្នែង។ ហ៊ើ...អ៊ំា! ហ៊ើ...អ៊ំា!! ពួកគេបានបញ្ចេញកំលាំងរបស់ពួកគេដើម្បីសែងបុរសនោះ ទៅកាន់កន្លែងដែលព្រះយេស៊ូគង់នៅ។

..........................................................................................



38Page

Narration　ប៉ុន្តែមានមនុស្សជាច្រើនបានប្រមូលផ្តុំគ្នានៅទីនោះ ដើម្បីមើលព្រះយេស៊ូ ដ្បិតគ្មានបន្ទប់ណាមួយបានទំនេរឡើយ។វាពិតជាមិនអាចទៅរួចនោះទេ ប្រសិនបើពួកគេត្រូវសែងបុរសពិការចូលទៅខាងក្នុងតាមច្រកទ្វានោះ។ ពួកគេគិតថាពួកគេនឹងហោះចូលទៅខាងក្នុង ប្រសិនបើពួកគេមានស្លាប ប៉ុន្តែវា............

មិត្តភក្តិទី១　ស្លាប? អូ!!!! ពិតជាគំនិតល្អមែន!!!

Narration　ថាម៉េច?

មិត្តភក្តិទី២　ត្រូវហើយ! ពួកយើងនឹងត្រូវឡើងទៅខាងលើ!!

Narration　ហា?? ចង់មានន័យថាម៉េច?

..........................................................................................



39Page

Narration　មិត្តភក្តិទាំងអស់បានសែងគាត់ឡើងទៅលើដំបូលផ្ទះ ដែលព្រះយេស៊ូកំពុងតែស្នាក់នៅ ហើយបានចោះដំបូលទំលាក់គាត់ចុះមក។

បុរសទី១　(ពេលនោះពិតជាមានសំឡេងរញ៉េរញ៉ៃណាស់) អូ? មើលណ៎!!

បុរសទី២　ដំបូលបាក់ចុះមកហើយ!!

បុរសទី៣　អ៊ំា!!!!!!!!

Narration　គ្រប់គ្នានៅក្នុងផ្ទះបានមើលទៅកាន់ដំបូល ពេលនោះគឺមានកន្ទ្រក់មួយ ដែលមិត្តភក្តិរបស់បុរសពិការបានយកខ្សែមកចងនឹងឈើស្នែងហើយទំលាក់គាត់ទៅជិតព្រះយេស៊ូ។ ប្រយ័ត្ន.........ប្រយ័ត្ន...........



40Page

**Narration** ហើយបុរសពិការក៏បានព្យាយាមទៅជិតព្រះយេស៊ូ តាមតែគេអាចធ្វើទៅបាន។

........................................................................................................

**Narration** ព្រះយេស៊ូបានឃើញពីជំនឿរបស់មិត្តភក្តិរបស់គាត់ ហើយទ្រង់បានសរសើរពួកគេ
រួចទ្រង់មានព្រះបន្ទូលទៅកាន់បុរសពិការនោះថា៖

**ព្រះយេស៊ូ** កូនប្រុស! ដ្បិតបាបរបស់អ្នកត្រូវបានលើកលែងហើយ ចូរក្រោកឈរ
ហើយយកគ្រែស្នែងរបស់អ្នកទៅផ្ទះវិញចុះ។

**Narration** បន្ទាប់ពីព្រះយេស៊ូមានព្រះបន្ទូលចប់ភ្លាម
បុរសដែលសូម្បីតែរំគិលខ្លួនក៏លំបាកដែលនោះ
បានក្រោកឈរហើយបានអរព្រះគុណព្រះយេស៊ូ។

**បុរសខ្វិន** វ៉ាវ!! ខ្ញុំអាចរំគិលបានហើយ!!
ខ្ញុំអាចដើរបានហើយ!!ព្រះយេស៊ូអរគុណទ្រង់ខ្លាំងណាស់ អរព្រះគុណទ្រង់។

**Narration** បុរសពិការបានសរសើរ និងថ្វាយសិរីរុងរឿងទៅកាន់ព្រះជាម្ចាស់
បន្ទាប់មកគាត់ក៏បានយកគ្រែស្នែងរបស់គាត់ត្រឡប់ទៅផ្ទះវិញ។
គ្រប់គ្នាទាំងអស់ដែលបានឃើញការនេះ ពិតជាស្ញើចសរសើរពីការអស្ចារ្យ
ហើយពួកគេបានថ្វាយសិរីរុងរឿងទៅកាន់ព្រះជាម្ចាស់។